អេស៊ីលីដា
ACLEDA BANK

# របាយការណ៍ប្រចាំត្រីមាសទី៤

## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាលានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ៣៧.១៨១.២៩៩ | ៣២.០០២.២៩៨ | ២៦.៥០០.៧៩៣ |
| បំណុលសរុប | ៣១.៧៦០.៦៦០ | ២៧.០៩២.៩៨៥ | ២២.០៩៣.២៥៨ |
| មូលធនសរុប | ៥.៤២០.៦៣៩ | ៤.៩០៩.៣១៣ | ៤.៤០៧.៥៣៥ |
| **លទ្ធផលហិរញ្ញវត្ថុ (គិតជាលានរៀល)** | **ត្រីមាសទី៤ ឆ្នាំ២០២២** | **ត្រីមាសទី៤ ឆ្នាំ២០២១** | **ត្រីមាសទី៤ ឆ្នាំ២០២០** |
| ចំណូលសរុប | ៨០៤.១៥៨ | ៦៧៣.៥៦៩ | ៦២២.០៤៧ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | ២៥០.៨៥១ | ២៣៦.១២០ | ២២២.១០៧ |
| ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ | ២០១.៤០២ | ១៨៩.៤៦៨ | ១៧៥.២៦៩ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ១៩៤.០៣១ | ១៥០.១៣២ | ១៧៧.១៣៥ |
| **អនុបាតហិរញ្ញវត្ថុ (%)** | **ត្រីមាសទី៤ ឆ្នាំ២០២២** | **ឆ្នាំ២០២១** | **ឆ្នាំ២០២០** |
| អនុបាតសាធនភាព | ១៩,២៥% | ២២,៣៦% | ២៥,១៥% |
| អនុបាតបំណុលធៀបនឹងមូលធន | ៥៨៥,៩២% | ៥៥១,៨៧% | ៥០១,២៦% |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព | ១៥៤,៩៦% | ១៥៥,៦៥% | ១៤៩,៣១% |
| អនុបាតឥណទានមិនដំណើរការ [(*)] | ២,៩០% | ២,៣៣% | ២,៤០% |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ១០០,៥១% | ៩៤,៩៧% | ៩៧,៧៣% |
| តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១២.៤៥៦ | ១១.២៧៧ | ១០.១៧៥ |
| | **ត្រីមាសទី៤ ឆ្នាំ២០២២** | **ត្រីមាសទី៤ ឆ្នាំ២០២១** | **ត្រីមាសទី៤ ឆ្នាំ២០២០** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)[(**)] | ០,៥៦% | ០,៦១% | ០,៦៧% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE)[(**)] | ៣,៨០% | ៣,៨៧% | ៤,០៣% |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ដង) | ១,៩២ | ២,២៣ | ២,៤៤ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៤៦៥,០០ | ៤៣៧,៣៧ | ៤០៤,៦៣ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | គ្មាន | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | គ្មាន | គ្មាន | គ្មាន |

(*) ឥណទានមិនដំណើរការ = ឥណទាននៅដំណាក់កាលទី៣

(**) . អនុបាតទាំងនេះមិនមែនជាអនុបាតប្រចាំឆ្នាំនោះទេ ហើយត្រូវបានគណនាដោយប្រើតួលេខប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគាររយៈពេល ៣ខែ ចាប់ពីថ្ងៃទី០១ ខែតុលា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

. ចំណេញធៀបនឹងមូលធនមធ្យម = ប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / មូលធនសរុបមធ្យមរបស់ភាគហ៊ុនិករបស់ធនាគារ

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប








អនុបាតហិរញ្ញវត្ថុ(%)
១៩,២៥%
២២,៣៦%
២៥,១៥%
៥៨៥,៩២%
៥៥១,៨៧%
៥០១,២៦%
១៥៤,៩៦%
១៥៥,៦៥%
១៤៩,៣១%
២,៩០%
២,៣៣%
២,៤០%
១០០,៥១%
៩៤,៩៧%
៩៧,៧៣%
អនុបាតសាធនភាព
អនុបាតបំណុលធៀបនឹងមូលធន
អនុបាតក្របខ័ណ្ឌសន្ទនីយភាព
អនុបាតឥណទានមិនដំណើរការ
អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ
ត្រីមាសទី៤ ឆ្នាំ២០២២
ឆ្នាំ២០២១
ឆ្នាំ២០២០




០,៥៦%
០,៦១%
០,៦៧%
៣,៨០%
៣,៨៧%
៤,០៣%
អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)
អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE)
ត្រីមាសទី៤ ឆ្នាំ២០២២
ត្រីមាសទី៤ ឆ្នាំ២០២១
ត្រីមាសទី៤ ឆ្នាំ២០២០


ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
៤០៤,៦៣
៤៣៧,៣៧
៤៦៥,០០
ត្រីមាសទី៤ ឆ្នាំ២០២០
ត្រីមាសទី៤ ឆ្នាំ២០២១
ត្រីមាសទី៤ ឆ្នាំ២០២២
ត្រីមាសទី៤ ឆ្នាំ២០២០
ត្រីមាសទី៤ ឆ្នាំ២០២១
ត្រីមាសទី៤ ឆ្នាំ២០២២


តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
១០.១៧៥
១១.២៧៧
១២.៤៥៦
ឆ្នាំ២០២០
ឆ្នាំ២០២១
ត្រីមាសទី៤ ឆ្នាំ២០២២
ឆ្នាំ២០២០
ឆ្នាំ២០២១
ត្រីមាសទី៤ ឆ្នាំ២០២២

# សមាសភាពក្រុមប្រឹក្សាភិបាល



**លោក ឆាយ សឿន**
*ប្រធានក្រុមប្រឹក្សាភិបាល*



**បណ្ឌិត អ៊ិន ចាន់នី**
*អភិបាលប្រតិបត្តិ*



**លោក រ័ត្ន យូម៉េង**
*អភិបាលប្រតិបត្តិ*



**លោក Stéphane Mangiavacca**
*អភិបាលមិនប្រតិបត្តិ*



**លោក Kyosuke Hattori**
*អភិបាលមិនប្រតិបត្តិ*



**លោក Albertus Bruggink**
*អភិបាលមិនប្រតិបត្តិ*



**លោក កាយ ឡូត**
*អភិបាលមិនប្រតិបត្តិ*



**លោក Pieter Kooi**
*អភិបាលឯករាជ្យ*



**លោក វ៉ាន់ ស៊ូអៀង**
*អភិបាលឯករាជ្យ*



**លោកស្រី ភួរិ រតនា**
*អភិបាលឯករាជ្យ*

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

តាងនាមឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ”) និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមផ្តល់ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ របស់ធនាគារ គិតចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដល់ភាគីពាក់ព័ន្ធទាំងអស់។

សេដ្ឋកិច្ចពិភពលោកបាន និងកំពុងប្រឈមនឹងបញ្ហាធ្ងន់ធ្ងរចាប់តាំងពីដើមឆ្នាំ២០២២ ដោយសារសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ការចំណាយប្រចាំថ្ងៃមានការកើនឡើងខ្ពស់ដោយសារសម្ពាធអតិផរណានៅតែបន្តមាន និងកាន់តែរីករាលដាលធំឡើង និងការថមថយកំណើនសេដ្ឋកិច្ចចិន។ សេដ្ឋកិច្ចអាស៊ានបានស្ទុះងើបឡើងវិញនៅឆ្នាំ២០២២ ដោយសារការបើកសកម្មភាពសេដ្ឋកិច្ចឡើងវិញ។ ទោះជាយ៉ាងណាក៏ដោយ សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងសន្ទុះកំណើនសេដ្ឋកិច្ចយឺត រួមផ្សំជាមួយនឹងបម្រែបម្រួលទីផ្សារមូលធនអាចបង្កហានិភ័យដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់ប្រទេសជាសមាជិកអាស៊ាន។

ទន្ទឹមនឹងនោះ នៅក្នុងឆ្នាំ២០២២ សេដ្ឋកិច្ចប្រទេសកម្ពុជាមានសន្ទុះងើបឡើងវិញ ដែលគាំទ្រដោយកំណើនសកម្មភាពពាណិជ្ជកម្ម ជាពិសេសកំណើនការនាំចេញក្នុងវិស័យផលិតកម្ម និងកសិកម្ម ព្រមទាំងបានស្ទុះងើបឡើងវិញនូវបរិយាកាសវិនិយោគ សកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងការងើបឡើងនូវវិស័យទេសចរណ៍បន្តិចម្តងៗ។ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងត្រឡប់ទៅរកកម្រិតធម្មតាដូចនៅមុនកូវីដ-១៩ នាឆ្នាំ២០២៣-២០២៤ ជាមួយនឹងការរំពឹងទុកនូវកំណើនយ៉ាងខ្លាំងនៃវិស័យផលិតកម្ម កសិកម្ម និងការងើបឡើងវិញនៃវិស័យទេសចរណ៍បន្តិចម្តងៗ។

នៅកំលុងត្រីមាសទី៤ ឆ្នាំ២០២២នេះ ធនាគារបានបន្តបង្កើនសមត្ថភាពប្រព័ន្ធ និងមុខងារស្វ័យប្រតិបត្តិការ ព្រមទាំងចុះកិច្ចព្រមព្រៀងជាមួយដៃគូអាជីវកម្មជាបន្តបន្ទាប់ ដើម្បីផ្តល់ជូនអតិថិជននូវសេវាកម្មធនាគារអេឡិចត្រូនិក ដែលកាន់តែងាយស្រួល សម្បូរបែប និងទូលំទូលាយ ប្រកបដោយសុវត្ថិភាពខ្ពស់បំផុត។ ធនាគារបានបង្កើនសមត្ថភាពប្រព័ន្ធធនាគារស្នូលដោយជោគជ័យ និងបន្តធ្វើឱ្យប្រសើរឡើងនូវមុខងារស្វ័យប្រតិបត្តិការជាច្រើនលើ**អេស៊ីលីដាម៉ូបាល** យូអរកូដ ម៉ាស៊ីនអេធីអឹម និងម៉ាស៊ីនឆូតកាត ស្របតាមតម្រូវការរបស់អតិថិជន និងវិវឌ្ឍនាការបច្ចេកវិទ្យាឌីជីថល។ ទន្ទឹមនឹងនេះ ធនាគារបានពង្រីកសេវាកម្មធនាគារស្វ័យប្រវត្តិចំនួន**១២៥**ទីតាំង (រាជធានីភ្នំពេញចំនួន**៥១**ទីតាំង និងបណ្តាខេត្តសរុបចំនួន**៧៤**ទីតាំង) បន្ថែមលើសាខាធនាគារទាំង**២៦៤**សាខា ព្រមទាំងបានបំពាក់ម៉ាស៊ីនអេធីអឹមចំនួន**១.១៤០**គ្រឿង ម៉ាស៊ីនឆូតកាតចំនួន**៤.៣៥៨**គ្រឿង និងយូអរកូដតាមសំណើសុំរបស់អតិថិជន សម្រាប់ប្រតិបត្តិការនៃការផ្ទេរ និងការទូទាត់នៅតាមបណ្តាផ្សារ ហាងទំនិញ សណ្ឋាគារ គ្រឹះស្ថានសិក្សា មន្ទីរពេទ្យ ទីភ្នាក់ងារទេសចរណ៍ ស្ថានីយប្រេងឥន្ធនៈ និងអាជីវកម្មនានានៅទូទាំងប្រទេស។ គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២២នេះ ធនាគារ មានដៃគូអាជីវកម្មសរុប **០,២លាន** និងមានអ្នកប្រើប្រាស់អេស៊ីលីដាម៉ូបាលសរុបចំនួន**២,៦១លាន**នាក់។

គិតត្រឹមដំណាច់ត្រីមាសទី៤ ឆ្នាំ២០២២នេះ ធនាគារសម្រេចបានលទ្ធផលជាវិជ្ជមាន ដោយទ្រព្យសកម្មសរុបបានកើនឡើងចំនួន ៦៥១,០៣ លានដុល្លារអាមេរិក ឬ ៧,៧៧% និងទ្រព្យសកម្មឥណទានសរុបបានកើនឡើងចំនួន ១៧៨,៧៦ លានដុល្លារអាមេរិក ឬ ២,៨៦% ធៀបនឹងដំណាច់ត្រីមាសទី៣ ឆ្នាំ២០២២។

ធនាគារទទួលបានប្រាក់ចំណេញដែលផ្តល់ជូនភាគហ៊ុនិករបស់ធនាគារ (សម្រាប់ខែតុលា វិច្ឆិកា និងធ្នូ ឆ្នាំ២០២២) សរុបចំនួន៤៨,៧៨ លានដុល្លារអាមេរិក ខណៈដែលអនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យមមានចំនួន ០,៥៦% និងអនុបាតចំណេញធៀបនឹងមូលធនមធ្យមមានចំនួន ៣,៨០%។

ជាទីបញ្ចប់ ខ្ញុំបាទសូមថ្លែងអំណរគុណ និងសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះភាគីពាក់ព័ន្ធទាំងអស់ដែលបានបន្តផ្តល់ការជ្រោមជ្រែង និងការគាំទ្រដល់ធនាគារ។

ថ្ងៃសុក្រ ៥រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣
ហត្ថលេខា និងត្រា

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

**ឆាយ សឿន**

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... ii

សមាសភាពក្រុមប្រឹក្សាភិបាល ..... v

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ..... vi

**ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១**

**ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១**

**ខ- លក្ខណៈនៃធុរកិច្ច ..... ១**

**គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១**

**ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ..... ៣**

**ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ..... ៣**

**ខ- រចនាសម្ព័ន្ធចំណូល ..... ៦**

**ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ ..... ៦**

**ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ..... ៧**

**ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ..... ៧**

**ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ..... ១០**

**គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ..... ១២**

**ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ..... ១២**

**ង- ផលប៉ះពាល់នៃអតិផរណា ..... ១២**

**ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ..... ១៣**

**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១៥**

# ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ អេស៊ីលីដា ភីអិលស៊ី** |
| ជាអក្សរឡាតាំង | **ACLEDA Bank Plc.** |
| លេខកូដស្តង់ដារ | KH១០០០១០០០០៣ |
| ទីស្នាក់ការ | អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (០)២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ |
| លេខទូរសារ | +៨៥៥ (០)២៣ ៤៣០ ៥៥៥ |
| គេហទំព័រ | www.acledabank.com.kh |
| អ៊ីម៉ែល | acledabank@acledabank.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៣០៧៧ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ០៦ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ចេញដោយ ធនាគារជាតិ នៃ កម្ពុជា |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ០៥៣/២០គ.ម.ក./ស.ស.រ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ចេញដោយនិយ័តករមូលបត្រកម្ពុជា “ន.ម.ក.” (ពីមុនជា គណៈកម្មការមូលបត្រកម្ពុជា “គ.ម.ក.”) |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | **បណ្ឌិត អ៊ិន ចាន់នី** |

## ខ- លក្ខណៈនៃធុរកិច្ច

ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារពាណិជ្ជដែលមានសាខា និងបណ្តាញការិយាល័យធំជាងគេបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា (ផមក) ចាប់តាំងពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។ បច្ចុប្បន្ននេះ ធនាគារមានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន៤ រួមមាន៖ (១) ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត (២) ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា (៣) ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរិធី ភីអិលស៊ី និង (៤) វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ព្រមទាំងមានការិយាល័យតំណាងចំនួន១នៅប្រទេសមីយ៉ាន់ម៉ា។

## គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

- នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ ភ្នាក់ងារវាយតម្លៃអន្តរជាតិ **Standard & Poor's (S&P) Global Ratings** បានរក្សាចំណាត់ថ្នាក់ **"B+/Stable/B"** សម្រាប់ធនាគារ។ ការរក្សាបាននូវចំណាត់ថ្នាក់នេះសបញ្ជាក់ថា ធនាគាររក្សាបាននូវស្ថិរភាពប្រតិបត្តិហិរញ្ញវត្ថុរបស់ខ្លួនក្នុងរយៈពេលវែង ជាមួយទ្រនាប់ដើមទុនគ្រប់គ្រាន់ ជួយឱ្យធនាគាររក្សាបាននូវស្ថិរភាពដើមទុនរបស់ខ្លួនសម្រាប់បង្ការផលប៉ះពាល់សេដ្ឋកិច្ចពីវិបត្តិកូវីដ-១៩ និងឧបសគ្គផ្សេងៗជាច្រើន ក្នុងម៉ាក្រូសេដ្ឋកិច្ច។

- នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ ធនាគារបានទទួល**លិខិតថ្លែងអំណរគុណ ពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ** ដែលធនាគារបានឧបត្ថម្ភថវិកាសម្រាប់ជួយគាំទ្រនូវឧបករណ៍ និងសម្ភារសង្គ្រោះលើផ្ទៃទឹក។ នេះសបញ្ជាក់ឱ្យឃើញថា ធនាគារបានរួមចំណែកជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីចូលរួមការពារ និងជួយការងារសង្គ្រោះប្រជាជន ដែលពិតជាមានតម្លៃក្នុងក្របខ័ណ្ឌមនុស្សធម៌ និងទឹកចិត្តសាមគ្គីភាពមិនអាចកាត់ថ្លៃបាន។

- នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២២ ធនាគារបានទទួលពានរង្វាន់ "**អភិវឌ្ឍន៍ជំនាញអាជីព នៃពានរង្វាន់ធុរកិច្ចអាស៊ានឆ្នាំ២០២២**" ពីកិច្ចប្រជុំកំពូលធុរកិច្ច និងវិនិយោគអាស៊ាន ឆ្នាំ២០២២ ដោយធនាគារបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍចំណេះជំនាញធនធានមនុស្ស និងចូលរួមចំណែកយ៉ាងសកម្មក្នុងវិស័យអប់រំនៅកម្ពុជា និងក្នុងតំបន់។ ធនាគារបានផ្តល់កម្មវិធីសិក្សាសម្រាប់និស្សិត និងផ្តល់វគ្គហ្វឹកហ្វឺនទាក់ទងនឹងវិស័យធនាគារ និងហិរញ្ញវត្ថុ ដល់សិក្ខាកាមជាច្រើនទាំងក្នុង និងក្រៅប្រទេស។

- នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ធនាគារបានទទួលការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា ក្នុងការបោះផ្សាយលក់សញ្ញាបណ្ណបៃតងសម្រាប់វិនិយោគិនគុណវុឌ្ឍិ។ ធនាគារកំពុងរៀបចំបំពេញតាមលក្ខខណ្ឌតម្រូវរបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) និងផ្សារមូលបត្រកម្ពុជា (ផមក)។ ការបោះផ្សាយលក់សញ្ញាបណ្ណបៃតងនេះ នឹងរួមចំណែកអនុវត្តតាមគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយការបំភាយឧស្ម័នកាបូនិច និងផលប៉ះពាល់បរិស្ថាន ព្រមទាំងការលើកកម្ពស់វិស័យមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

- នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ធនាគារបានទទួល**លិខិតថ្លែងអំណរគុណ**ពីក្រសួងអប់រំ យុវជន និងកីឡា ដែលធនាគារបានចូលរួមឧបត្ថម្ភគាំទ្រកម្មវិធី "ប្រកួតប្រជែងស្នាដៃយុវជនសតវត្សទី២១" ក្រោមប្រធានបទ "**STEM និងការប្រើប្រាស់ក្នុងវិស័យបរិស្ថាន**" ប្រចាំឆ្នាំ២០២២។

- នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២២ ធនាគារបានទទួល**លិខិតថ្លែងអំណរគុណ**ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលធនាគារបានចូលរួមអនុវត្តនូវ "**គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម**" ជាមួយធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជាកន្លងមក។ នេះជាសក្ខីភាពបញ្ជាក់ពីការចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

- នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២២ ធនាគារបានទទួល**លិខិតថ្លែងអំណរគុណ**ពីមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" ដែលធនាគារបានឧបត្ថម្ភក្នុងកម្មវិធីនវានុវត្តន៍ "បញ្ញាស២០២២ (រដូវកាលទី២)" ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"។ នេះសបញ្ជាក់ឱ្យឃើញថា ធនាគារបានយកចិត្តទុកដាក់ ក្នុងការចូលរួមចំណែកអភិវឌ្ឍវិស័យបច្ចេកវិទ្យា តាមរយៈកម្មវិធីនវានុវត្តន៍ឱ្យកាន់តែប្រសើរឡើងជាបន្តបន្ទាប់។

- នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២ ធនាគារបានចុះកិច្ចព្រមព្រៀងជាមួយនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ស្តីពីការប្រើប្រាស់សេវាទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់ការបង់ថ្លៃសេវាស្នើសុំលេខអត្តសញ្ញាណវិនិយោគិនតាមអនឡាញ។ តាមរយៈកិច្ចព្រមព្រៀងនេះ វិនិយោគិនអាចទូទាត់ថ្លៃសេវាស្នើសុំលេខអត្តសញ្ញាណវិនិយោគិនតាមអនឡាញ មានដូចជា ការទូទាត់តាមរយៈប្រព័ន្ធ **X-Pay** (ACLEDA Bank Plc. Local Payment Gateway) ឬ **អេស៊ីលីដាម៉ូបាល** (Deep-Link) ឬប្រព័ន្ធ **MPGS** (ការទូទាត់ពីប័ណ្ណអន្តរជាតិមាន ដូចជា VISA Mastercard Diners JCB និង UPI Card) ប្រកបដោយភាពងាយស្រួល និងមានសុវត្ថិភាពខ្ពស់។

- នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ធនាគារបានបើកដំណើរការសាខាថ្មី**ទី២៦៤ (សាខាអ៊ីអនមានជ័យ)** នៅក្នុងផ្សារទំនើបអ៊ីអនម៉លមានជ័យ។ សាខានេះត្រូវបានបង្កើតឡើង ដើម្បីបន្ថែមម៉ោងបម្រើសេវាកម្មជូនអតិថិជន ដូចគ្នានឹងសាខាសុធារស និងសែនសុខ (ផ្សារអ៊ីអន) ដែលបើកបម្រើសេវាកម្ម៧ថ្ងៃក្នុង១សប្តាហ៍ ចាប់ពីម៉ោង៩:០០ ដល់ម៉ោង១៩:០០ បន្ថែមលើសាខា និងសេវាកម្មធនាគារស្វ័យប្រវត្តិរបស់ខ្លួននៅរាជធានីភ្នំពេញ។

- នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ ក្រសួងមុខងារសាធារណៈ សហការចូលរួមដោយធនាគារ អេស៊ីលីដា និងធនាគារពាណិជ្ជ២ ផ្សេងទៀត បានរៀបចំកម្មវិធីដាក់ឱ្យប្រើប្រាស់ **អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិលប្រភេទថ្មី "ស្មាតកាត"**។ ព្រឹត្តិការណ៍នេះបានសបញ្ជាក់ពីវឌ្ឍនភាព នៃកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងការចូលរួមអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា និងរួមចំណែកដល់ការអភិវឌ្ឍរីកចម្រើនឥតឈប់ឈររបស់សង្គមជាតិ។ ទន្ទឹមនឹងនេះ ធនាគារត្រូវបានជ្រើសរើស និងអនុញ្ញាតដោយក្រសួងមុខងារសាធារណៈឱ្យបោះពុម្ព និងផ្តល់ **អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិលប្រភេទថ្មី "ស្មាតកាត"** នេះ ជូនដល់មន្ត្រីរាជការ សម្រាប់ប្រើប្រាស់ជាប័ណ្ណសម្គាល់ខ្លួនផ្លូវការផង និងជាប័ណ្ណអេធីអឹមផង ដែលអាចដាក់-ដកប្រាក់បៀវត្សពីធនាគារ និងអាចប្រើប្រាស់ជាមធ្យោបាយចាំបាច់ផ្សេងៗ ទៀត។

# ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

- **ប្រតិបត្តិការក្នុងវិស័យធនាគារ**

ត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២២ ធនាគារពាណិជ្ជមានចំនួន៥៩ (ធនាគារក្នុងស្រុកចំនួន២៧ បុត្រសម្ព័ន្ធធនាគារបរទេសចំនួន១៨ និងសាខាធនាគារបរទេសចំនួន១៤) ធនាគារឯកទេសចំនួន០៩ (ធនាគារក្នុងស្រុកចំនួន០៤ និងធនាគារបរទេសចំនួន០៥) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៨៧ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន០៥ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន៨២) ក្រុមហ៊ុនភតិសន្យាចំនួន១៦ ការិយាល័យតំណាងធនាគារបរទេសចំនួន០៦ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន៣៨ និងគ្រឹះស្ថានឥណទានជនបទចំនួន២២៤។ (Source: NBC Report, CMA Report, and Actually Updated)

- **ប្រតិបត្តិការអាជីវកម្ម និងចំណែកទីផ្សាររបស់ធនាគារ អេស៊ីលីដា នៅក្នុងវិស័យធនាគារ**

គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២២ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានចំណែកទីផ្សារសម្រាប់ប្រាក់បញ្ញើសន្សំចំនួន ១៦,១៣% និងសម្រាប់ឥណទានចំនួន ១៣,៦១%។

គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២២ ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៤ ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
| **សេវាឥណទាន** | | | |
| ចំនួនឥណទានសកម្ម | ៥៩១.៤៩៤ | ៥៤១.១៨៤ | ៥៥៥.៣២៣ |
| សមតុល្យឥណទានសរុប (លានរៀល) | ២៦.៤៣៧.៩២៨ | ២២.១១៦.០១៣ | ១៨.២២៩.៣៧២ |
| **សេវាបញ្ញើ-សន្សំ** | | | |
| ចំនួនគណនីសរុប | ៣.៨២៥.៧៤៩ | ៣.២៩៨.៣៨២ | ២.៨៩៤.៩០៧ |
| សមតុល្យប្រាក់បញ្ញើសរុប (លានរៀល) | ២៦.៣០៣.៤៧៥ | ២៣.២៨៧.០៦៤ | ១៨.៦៥២.៦៩០ |
| **សេវាធនាគារអេឡិចត្រូនិក** | | | |
| **ប័ណ្ណអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណបោះផ្សាយសរុប | ១.៧៩៩.៩០៩ | ១.៥៨៥.៤៤៩ | ១.៣៩៦.៧៧៨ |
| ចំនួនប្រតិបត្តិការសរុប | ២១.០៥៨.៦០៩ | ១៩.៤៤៨.៨៣៧ | ១៩.៧៦៨.២២៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៨.៦៨៣.៣៣៥ | ១៦.១៧៣.៩៩០ | ១៣.៧៧៥.៩១៨ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៤ ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
| **អេស៊ីលីដាម៉ូបាល** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ២.៨៤៥.៨៨៦ | ២.២៧៨.២២០ | ១.៧៨២.៨១៤ |
| ចំនួនប្រតិបត្តិការសរុប | ១៤៨.៧៩៩.៦៦១ | ៧៨.៧២៦.៨៩៥ | ៤៨.៧៤៩.៥៩៩ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២០៦.៦៦០.២៦២ | ១១៥.២៤២.៦៣៨ | ៥៩.២១១.២៧៩ |
| **អេស៊ីលីដាអ៊ីនធើណែត** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ២២.១៦៤ | ១៣.៥៥៧ | ១១.៦៧៩ |
| ចំនួនប្រតិបត្តិការសរុប | ២.៣១៨.៧៨៩ | ១.៤៦៦.៨២២ | ៨៨៦.៩៩០ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២៦.១៥៨.៧០៥ | ១៩.៧៩៩.៨៦៤ | ១១.២៨៥.៩៤៨ |
| **អេស៊ីលីដាអ៊ីខុមមើស** | | | |
| ចំនួនដៃគូអាជីវកម្មសរុប | ៧៣ | ៥៩ | ៥១ |
| ចំនួនប្រតិបត្តិការសរុប | ៣.៦១៩.៩៣៦ | ៣.២១៥.២០៧ | ៤៤៧.៩២៩ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១.៨០៤.១៣៦ | ១.២០៦.៥២៩ | ៣៦០.០០០ |
| **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនសរុប | ១.១១៤ | ៩០១ | ៧៥៧ |
| ចំនួនប្រតិបត្តិការសរុប | ៣៥.២៩៨.២១៤ | ២៧.១២៩.២៥២ | ២៦.៥៧២.៧៧១ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៣៩.១៦០.៩៧៦ | ២៦.៤៧៧.៣៤១ | ២០.០១៨.៤៣២ |
| **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** | | | |
| ចំនួនម៉ាស៊ីនសរុប | ២៦ | ២៦ | ១៤ |
| ចំនួនប្រតិបត្តិការសរុប | ១.៤៨៧ | ៤.១២០ | ១.៩០៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១១១.១៣៤ | ៣៤៣.១៥៨ | ១៨០.២៩២ |
| **ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម** | | | |
| ចំនួនម៉ាស៊ីនសរុប | ៤៣ | ២៥ | - |
| ចំនួនប្រតិបត្តិការសរុប | ៤៣.០៨៩ | ៣៤.០៩២ | - |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៦ | ៧០ | - |
| **ម៉ាស៊ីនទទួលកាបូបប្រាក់** | | | |
| ចំនួនម៉ាស៊ីនសរុប | ១៧ | ១៤ | ១៩ |
| ចំនួនប្រតិបត្តិការសរុប | ៧៥.០២០ | ៩៤.៧១៣ | ១២១.១៩៨ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៥៧១.០៩៨ | ៥៥៥.២៥៧ | ៨៣០.៤០៨ |
| **ម៉ាស៊ីនឆូតកាតអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនឆូតកាតសរុប | ៤.៣៥៨ | ៤.៤៦២ | ៤.២៨៧ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៤ ឆ្នាំ២០២២ | ឆ្នាំ២០២១ | ឆ្នាំ២០២០ |
| ចំនួនប្រតិបត្តិការសរុប | ២.១៥៩.១៧៥ | ២.០៣៣.២៨៣ | ២.៤៥៧.៦២៦ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៥៩១.៦០៣ | ៤៧៩.៦១៣ | ៦៥៧.៥០៦ |
| **ឃ្យូអរ ពាណិជ្ជករ** | | | |
| ចំនួនពាណិជ្ជករ | ២៣៩.៧៥១ | ១២៥.៣០៩ | ៦៣.៧១៤ |
| ចំនួនប្រតិបត្តិការសរុប | ១៦.៤៥៩.៣៧៧ | ៣.១៩៤.៤៤៣ | ១.៨៤២.៩១៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៧.៧៧៧.៤៩១ | ៦៣៨.២៤០ | ១៨៦.៦៩១ |
| **អេស៊ីលីដាអ៊ីសប** | | | |
| ចំនួនផ្សារអនឡាញ | ៤ | ១ | - |
| ចំនួនប្រតិបត្តិការសរុប | ១៨ | ២៨៦ | - |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ០,៣៩ | ៧ | - |
| **ប័ណ្ណនិម្មិតអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណនិម្មិត | ៨.៨៩៨ | ៣.៦៨៤ | - |
| ចំនួនប្រតិបត្តិការសរុប | ៣៤.៩០៧ | ២.៤៩១ | - |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៣.០១៨ | ១៦១ | - |
| **ខ្សែអាយប៉ែង** | | | |
| ចំនួនខ្សែបោះផ្សាយសរុប | ៤.៩៦០ | - | - |
| ចំនួនប្រតិបត្តិការសរុប | ១៨.៧៤២ | - | - |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៣១.៧៦២ | - | - |
| **បណ្ដាញប្រតិបត្តិការ និង បុគ្គលិក** | | | |
| **ធនាគារ អេស៊ីលីដា ភីអិលស៊ី** | | | |
| ចំនួនការិយាល័យសរុប | ២៦៤ | ២៦២ | ២៦៣ |
| ចំនួនធនាគារស្វ័យប្រវត្តិ | ១២៥ | ៧៣ | ៣៧ |
| ចំនួនបុគ្គលិកសរុប | ១២.០៨៣ | ១២.០៨១ | ១២.០១៣ |
| **ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ក្នុង និង ក្រៅប្រទេស)** | | | |
| ចំនួនការិយាល័យសរុប | ៥៦ | ៥៧ | ៥៦ |
| ចំនួនបុគ្គលិកសរុប | ១.៤៩៩ | ១.៥៩៣ | ១.៦៩១ |

## ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២២ | | ត្រីមាសទី៤ ឆ្នាំ២០២១ | | ត្រីមាសទី៤ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៧៣៤.៤៦០ | ៩១,៣៣% | ៦០២.១២៨ | ៨៩,៣៩% | ៥៤៨.០៤៥ | ៨៨,១០% |
| ២ | ចំណូលកម្រៃនិងជើងសា | ៤៦.៧៨៩ | ៥,៨២% | ៤២.៩៦៨ | ៦,៣៨% | ៤៨.០៩៧ | ៧,៧៣% |
| ៣ | ចំណូលផ្សេងៗសុទ្ធ | ២២.៩០៩ | ២,៨៥% | ២៨.៤៧៣ | ៤,២៣% | ២៥.៩០៥ | ៤,១៦% |
| **ចំណូលសរុប** | | **៨០៤.១៥៨** | **១០០%** | **៦៧៣.៥៦៩** | **១០០%** | **៦២២.០៤៧** | **១០០%** |

# ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនកររឯករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ
របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនកររឯករាជ្យ

# ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះផ្តោតសំខាន់លើលទ្ធផលប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេលគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុចន្លោះពេលត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ហ.អ.ក)។ មានតែសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេល និងកត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ប៉ុណ្ណោះ ត្រូវបានយកមកធ្វើការពិភាក្សា និងវិភាគ។

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១- ការវិភាគចំណូល

ធនាគារ អេស៊ីលីដា ភីអិលស៊ី មានប្រភពចំណូលធំៗចំនួនបីគឺ ចំណូលការប្រាក់ ចំណូលកម្រៃនិងជើងសា និងចំណូលផ្សេងៗសុទ្ធ។

- ចំណូលការប្រាក់៖ រួមមានចំណូលការប្រាក់ពីឥណទាននិងបុរេប្រទាន ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងការវិនិយោគហិរញ្ញវត្ថុ។
- ចំណូលកម្រៃនិងជើងសា៖ រួមមានកម្រៃជើងសា កម្រៃជើងសាបានពីភ្នាក់ងារធានារ៉ាប់រង កម្រៃពីម៉ាស៊ីនអេធីអឹម កម្រៃពីការសងឥណទានមុនកាលកំណត់ កម្រៃពីសេវាប្រាក់បញ្ញើ កម្រៃពីសេវាធានា និងកម្រៃពីការបណ្តុះបណ្តាល។
- ចំណូលផ្សេងៗសុទ្ធ៖ រួមមានចំណេញពីការប្តូររូបិយប័ណ្ណ ចំណេញពីការលក់ទ្រព្យនិងបរិក្ខារ ភាគលាភលើការវិនិយោគហិរញ្ញវត្ថុ និងចំណូលផ្សេងៗ។

### ២- ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២២ | | ត្រីមាសទី៤ ឆ្នាំ២០២១ | | ត្រីមាសទី៤ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៧៣៤.៤៦០ | ៩១,៣៣% | ៦០២.១២៨ | ៨៩,៣៩% | ៥៤៨.០៤៥ | ៨៨,១០% |
| ២ | ចំណូលកម្រៃនិងជើងសា | ៤៦.៧៨៩ | ៥,៨២% | ៤២.៩៦៨ | ៦,៣៨% | ៤៨.០៩៧ | ៧,៧៣% |
| ៣ | ចំណូលផ្សេងៗសុទ្ធ | ២២.៩០៩ | ២,៨៥% | ២៨.៤៧៣ | ៤,២៣% | ២៥.៩០៥ | ៤,១៦% |
| | **ចំណូលសរុប** | **៨០៤.១៥៨** | **១០០%** | **៦៧៣.៥៦៩** | **១០០%** | **៦២២.០៤៧** | **១០០%** |

ចំណូលសរុបចំនួន ៨០៤,១៦ ប៊ីលានរៀល ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ភាគច្រើនបានមកពីចំណូលការប្រាក់ដែលមានចំណែក ៩១,៣៣% នៃចំណូលសរុប និងចំណូលសរុបបានកើនឡើងចំនួន ១៣០,៥៩ ប៊ីលានរៀល ឬ ១៩,៣៩% បើប្រៀបធៀបទៅនឹងត្រីមាសទី៤ ឆ្នាំ២០២១។

### ៣- ការវិភាគគម្លាតចំណេញដុល

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរបស់ធនាគារ បានរៀបចំក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីគម្លាតចំណេញដុលទេ។ ចំណូលការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់សរុប នឹងត្រូវយកមកបង្ហាញនៅក្នុងការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ ដូចខាងក្រោម។

## ៤- ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២២ | ត្រីមាសទី៤ ឆ្នាំ២០២១ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ៧៣៤.៤៦០ | ៦០២.១២៨ | ១៣២.៣៣២ | ២១,៩៨% |
| ចំណាយការប្រាក់ | (២៧១.២៩២) | (១៩១.៧៤៤) | (៧៩.៥៤៨) | ៤១,៤៩% |
| **ចំណូលការប្រាក់សុទ្ធ** | **៤៦៣.១៦៨** | **៤១០.៣៨៤** | **៥២.៧៨៤** | **១២,៨៦%** |
| ចំណូលកម្រៃនិងជើងសា | ៤៦.៧៨៩ | ៤២.៩៦៨ | ៣.៨២១ | ៨,៨៩% |
| ចំណាយកម្រៃនិងជើងសា | (៤.៨០៧) | (៣.៥៥៦) | (១.២៥១) | ៣៥,១៨% |
| **ចំណូលកម្រៃនិងជើងសាសុទ្ធ** | **៤១.៩៨២** | **៣៩.៤១៣** | **២.៥៦៩** | **៦,៥២%** |
| សំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃរបស់ឥណទាន និងបុរេប្រទាន ប្រាក់បញ្ញើនៅធនាគារផ្សេងៗ គណនីត្រូវទទួល និងមូលបត្រវិនិយោគផ្សេងៗ | (២.៤៤៤) | ២០.៤៥៤ | (២២.៨៩៨) | ១១១,៩៥% |
| សំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃកិច្ចសន្យាក្រៅតារាងតុល្យការ | ១ | ៦៦ | (៦៥) | ៩៨,៤៨% |
| **ចំណាយពីការខាតបង់ឱនភាពនៃតម្លៃសុទ្ធ** | **(២.៤៤៣)** | **២០.៥២០** | **(២២.៩៦៣)** | **១១១,៩១%** |
| **ចំណូលបន្ទាប់ពីការខាតបង់ឱនភាពនៃតម្លៃ** | **៥០២.៧០៧** | **៤៧០.៣១៦** | **៣២.៣៩១** | **៦,៨៩%** |
| ចំណូលផ្សេងៗសុទ្ធ | ២២.៩០៩ | ២៨.៤៧៣ | (៥.៥៦៤) | (១៩,៥៤%) |
| ចំណាយទូទៅនិងរដ្ឋបាល | (២៧៤.៧៦៤) | (២៦២.៦៦៩) | (១២.០៩៥) | ៤,៦០% |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **២៥០.៨៥១** | **២៣៦.១២០** | **១៤.៧៣១** | **៦,២៤%** |

ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញនៅត្រីមាសទី៤ ឆ្នាំ២០២២ បានកើនឡើងចំនួន ១៤,៧៣ ប៊ីលានរៀល ឬ ៦,២៤% បើប្រៀបធៀបទៅនឹងត្រីមាសទី៤ ឆ្នាំ២០២១ ដោយសារភាគច្រើនមកពីការកើនឡើងនូវចំណូលការប្រាក់សុទ្ធចំនួន ៥២,៧៨ ប៊ីលានរៀល ចំណូលកម្រៃនិងជើងសាសុទ្ធចំនួន ២,៥៧ ប៊ីលានរៀល និងកាត់បន្ថយដោយការកើនឡើងនូវចំណាយពីការខាតបង់ឱនភាពនៃតម្លៃសុទ្ធចំនួន ២២,៩៦ ប៊ីលានរៀល និងចំណាយទូទៅនិងរដ្ឋបាលចំនួន ១២,១០ ប៊ីលានរៀល ខណៈដែលចំណូលផ្សេងៗសុទ្ធ ថយចុះចំនួន ៥,៥៦ ប៊ីលានរៀល។

## ៥- ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២២ | ត្រីមាសទី៤ ឆ្នាំ២០២១ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **២៥០.៨៥១** | **២៣៦.១២០** | **១៤.៧៣១** | **៦,២៤%** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៤៩.៤៤៩) | (៤៦.៦៥២) | (២.៧៩៧) | ៦,០០% |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **២០១.៤០២** | **១៨៩.៤៦៨** | **១១.៩៣៤** | **៦,៣០%** |

## ៦- ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| លទ្ធផលលម្អិតសរុប (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២២ | ត្រីមាសទី៤ ឆ្នាំ២០២១ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **២០១.៤០២** | **១៨៩.៤៦៨** | **១១.៩៣៤** | **៦,៣០%** |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | |
| **ធាតុដែលនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញទៅចំណេញ ឬខាត៖** | | | | |
| ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | ១.៩៣៦ | (១៧.០៨៧) | ១៩.០២៣ | ១១១,៣៣% |
| លម្អៀងពីអត្រាប្តូរប្រាក់ | (២.៤៥៧) | (៦.១៨៥) | ៣.៧២៨ | ៦០,២៧% |
| **ធាតុដែលត្រូវ ឬអាចត្រូវបានចាត់ថ្នាក់ឡើងវិញនៅគ្រាបន្ទាប់ទៅចំណេញ ឬខាត៖** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ-ក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស | (៤.៧៤៨) | (១៤.០០៤) | ៩.២៥៦ | ៦៦,១០% |
| ការវាស់វែងឡើងវិញលើផ្នែកដែលមានប្រសិទ្ធភាពរបស់ឧបករណ៍និស្សន្ទដែលកើតឡើងពីការការពារហានិភ័យលំហូរសាច់ប្រាក់ | (២.១០២) | (២.០៦០) | (៤២) | (២,០៤%) |
| **លទ្ធផលលម្អិតផ្សេងៗក្នុងការិយបរិច្ឆេទ** | **(៧.៣៧១)** | **(៣៩.៣៣៦)** | **៣១.៩៦៥** | **៨១,២៦%** |
| **លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | **១៩៤.០៣១** | **១៥០.១៣២** | **៤៣.៨៩៩** | **២៩,២៤%** |

## ៧- ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ធនាគារ អេស៊ីលីដា មានទំនុកចិត្តក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការរបស់ខ្លួន ចំពេលការព្យាករកំណើនសេដ្ឋកិច្ចមានសញ្ញាល្អប្រសើរឡើង បន្ទាប់ពីបានកសាងកេរ្តិ៍ដំណែលដ៏រឹងមាំអស់រយៈពេល ៣០ឆ្នាំកន្លងមកនេះ ធនាគារ អេស៊ីលីដា បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ពេលអនាគត ហើយនឹងនៅតែបន្តចាក់គ្រឹះឱ្យកាន់តែរឹងមាំដើម្បីផ្តល់ជូននូវដំណោះស្រាយក្នុងវិស័យធនាគារឱ្យកាន់តែសម្បូរបែប ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរតម្រូវការផ្នែកហិរញ្ញវត្ថុរបស់អតិថិជនទាំងនៅក្នុង និងក្រៅប្រទេសកម្ពុជា។

បន្ទាប់ពីបំបែកព្រំដែនភូមិសាស្ត្រ ដោយការដាក់បញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងរូបវន្ត ធនាគារដែលបានបង្កើតឡើងនៅក្នុងស្រុកមួយនេះ កំពុងផ្តល់ជូននូវសេវាកម្មធនាគារសម្រាប់មូលដ្ឋានអតិថិជនចម្រុះដោយជោគជ័យ ដែលមានរាប់ចាប់តាំងពីសេវាធនាគារបុគ្គល និងសម្រាប់សាជីវកម្ម ទាំងនៅក្នុងទីក្រុង រហូតដល់តំបន់ជនបទ។ ជាមួយនឹងភាពលេចធ្លោក្នុងការផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដ៏សម្បូរបែប ដូចជាផ្តល់ប្រាក់កម្ចី ផ្ទេរប្រាក់ ប្រាក់បញ្ញើ ហិរញ្ញប្បទានពាណិជ្ជកម្ម អេស៊ីលីដាអ៊ីនធើណែត អេស៊ីលីដាម៉ូបាល និងសេវាសំខាន់ជាច្រើនទៀត គាំទ្រដោយហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការិយាល័យរូបវន្តរបស់ខ្លួន ធនាគារ អេស៊ីលីដា កំពុងចូលរួមយ៉ាងសកម្មក្នុងការជួយដល់កសិករ តាមរយៈការផ្តល់ដើមទុនសម្រាប់ធ្វើស្រែចម្ការរបស់គាត់ ឬផ្តល់ទុនសម្រាប់សហគ្រាសធុនតូច និងមធ្យមជាដើម។ តាមរយៈការបង្រួមគម្លាតចំពោះការទទួលបានហិរញ្ញប្បទានសព្វថ្ងៃនេះប្រជាជនកម្ពុជាច្រើនជាងកន្លះលាននាក់ មានលទ្ធភាពប្រើប្រាស់សេវារបស់ធនាគារ អេស៊ីលីដា ដែលជាការជំរុញនិងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។

សម្រាប់រយៈពេល៣០ឆ្នាំខាងមុខ គេនឹងមើលឃើញ ធនាគារ អេស៊ីលីដា គឺជា ធនាគារឌីជីថល ដែលមានវិស្វកម្មគ្រប់គ្រងទិន្នន័យទំនើបទាន់សម័យ (Data Lakehouse) ប្រកបដោយគុណភាព សុវត្ថិភាព និងទំនុកចិត្ត។ ប្រព័ន្ធអេកូនៃបណ្ដាញប្រកបដោយប្រសិទ្ធភាពរបស់ធនាគារនៅទូទាំងប្រទេស រួមមានម៉ាស៊ីន ATM ទីតាំងធនាគារស្វ័យប្រវត្តិ ម៉ាស៊ីនដក-ដាក់ប្រាក់ ម៉ាស៊ីនបើកគណនីនិងបោះពុម្ពប័ណ្ណអេធីអឹម ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ កំពុងដើរតួជាកាតាលីករដ៏មានឥទ្ធិពលមួយសម្រាប់រលកនៃកំណើនបន្ទាប់។

អនាគតរបស់ធនាគារនឹងកាន់តែរឹងមាំ ខណៈទំនុកចិត្តរបស់អាជីវកម្មលើកំណើនសេដ្ឋកិច្ចរបស់កម្ពុជានឹងកើនឡើង បន្ទាប់ពីរាជរដ្ឋាភិបាលបានទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទស្សនៈវិស័យកំណើនរបស់ប្រទេសកម្ពុជា ត្រូវបានរំពឹងថានឹងងើបឡើងវិញនៅពេលដែលការរឹតបន្តឹងបញ្ហាកូវីដ-១៩ ត្រូវបានដកចេញ។

ការងើបឡើងវិញនៃការនាំចេញផ្នែកផលិតកម្ម និងការពង្រីកការនាំចេញទំនិញកសិកម្ម នឹងមានភាពល្អប្រសើរសម្រាប់ធនាគារ អេស៊ីលីដា ដោយសារអ្នកទទួលកម្ចីភាគច្រើនមានអាជីវកម្មទាក់ទងនឹងកសិផល។ ធនាគារសម្រេចបានលទ្ធផលកាន់តែល្អប្រសើរនៅក្នុងឆ្នាំ២០២២ ដោយសារធនាគារបានវិនិយោគយ៉ាងច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល សាងសង់មជ្ឈមណ្ឌលទិន្នន័យដ៏ធំមួយ ដែលមានសុវត្ថិភាពខ្ពស់ដើម្បីរក្សាទុកទិន្នន័យ។ ការសាងសង់មជ្ឈមណ្ឌលការពារទិន្នន័យ (Disaster Recovery Data Center) នឹងជួយរក្សាទិន្នន័យនៅក្នុងបរិយាកាសដែលមានការការពារខ្ពស់។ ធនាគារមានទំនុកចិត្តចំពោះពេលអនាគត ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងផលិតផល-សេវាកម្ម ដែលនឹងកាន់តែមានភាពល្អប្រសើរ។

## ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ធនាគារ អេស៊ីលីដា ទទួលបានជោគជ័យនៅលើទីផ្សារដែលនាំមកនូវផលចំណេញអាស្រ័យដោយកត្តាពីរគឺៈ

- កំណើនសំពៀតឥណទាន ដោយសារតម្រូវការខ្ពស់នៅលើទីផ្សារលើផលិតផលឥណទានរបស់ធនាគារ ជាពិសេសសហគ្រាសធុនតូច និងមធ្យម។
- កំណើនប្រាក់បញ្ញើ-សន្សំ របស់ធនាគារ រួមជាមួយផលិតផល និងសេវាកម្មផ្សេងទៀត។

កត្តាទាំងពីរនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងការអភិវឌ្ឍឥតឈប់ឈរនៃប្រព័ន្ធឌីជីថលរបស់ធនាគារ ដែលផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងទាន់សម័យ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី បាននិងកំពុងតែអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធចម្រុះឱ្យកាន់តែទូលំទូលាយសម្រាប់ជាជម្រើសដ៏សម្បូរបែបជាមួយនឹងការិយាល័យទាំង៣២០ តាមរយៈការផ្លាស់ប្តូរបន្តិចម្តងៗទៅជាមជ្ឈមណ្ឌលដែលអាចធ្វើស្វ័យប្រតិបត្តិការដែលមានទីតាំងធនាគារស្វ័យប្រវត្តិចំនួន១២៥ ព្រមទាំងមាន **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** ចំនួន១.១១៤គ្រឿង **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** ចំនួន២៦គ្រឿង **ម៉ាស៊ីនបើកគណនីនិងបោះពុម្ពប័ណ្ណអេធីអឹម** ចំនួន៤៣គ្រឿង **ម៉ាស៊ីនទទួលកាបូបប្រាក់** ចំនួន១៧គ្រឿង និង**ម៉ាស៊ីនឆូតកាត**ចំនួន៤.៣៥៨គ្រឿង។ ចំណុចគួរជាទីមោទកភាពគឺធនាគារ អេស៊ីលីដា បានបោះពុម្ពប័ណ្ណ**អេធីអឹមអេស៊ីលីដា** ចំនួន១,៨០លានប័ណ្ណជូនដល់អតិថិជន។ បន្ថែមលើនេះ ធនាគារបានផ្តល់ **ខ្សែអាយប៉ែង** ច្រើនជាង ៤ពាន់ខ្សែដល់អតិថិជន។ ទន្ទឹមនឹងនេះ **អេស៊ីលីដាម៉ូបាល** បានទទួលប្រជាប្រិយភាពយ៉ាងខ្លាំងដែលចំនួននៃអ្នកចុះឈ្មោះប្រើប្រាស់បានកើនដល់ ២,៨៥លាននាក់ នៅដំណាច់ខែធ្នូ ឆ្នាំ២០២២នេះ ដែលអាចជួយឱ្យចរាចរសាច់ប្រាក់បានឆាប់រហ័សនៅក្នុងសេដ្ឋកិច្ច។

ការបង្កើនភាពងាយស្រួលដល់អតិថិជន និងពង្រឹងប្រព័ន្ធសុវត្ថិភាពអ៊ីនធើណែត គឺជាចំណុចដែលធនាគារ អេស៊ីលីដា ផ្តោតការយកចិត្តទុកដាក់បំផុត។ ដើម្បីសម្រេចនូវវឌ្ឍនភាពគោលដៅដ៏រឹងមាំទាំងនេះ ធនាគារនឹងបន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមរយៈការវិនិយោគលើបច្ចេកវិទ្យាទំនើបចុងក្រោយ ពង្រឹងសមត្ថភាពធនធានមនុស្ស ព្រមទាំងពង្រីកនិងកែលម្អដំណើរការអាជីវកម្ម។ ជាយុទ្ធសាស្ត្រ ធនាគារកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដែលអាចឱ្យដៃគូទាំងក្នុង និងក្រៅប្រទេសអាចភ្ជាប់ប្រព័ន្ធនេះដើម្បីបម្រើអតិថិជនទៅវិញទៅមក និងឆ្លងព្រំដែន។ ប្រព័ន្ធនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់អតិថិជន

ដ៏ឆ្លាតវៃរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដៃគូអាជីវកម្មរបស់ពួកគាត់ផងដែរ។ យើងខ្ញុំទទួលស្គាល់ថាអតិថិជន និងដៃគូអាជីវកម្មទាំងអស់គឺជាបណ្តាញតភ្ជាប់ដ៏មានសារសំខាន់សម្រាប់ពង្រីកសេវាកម្មរបស់ធនាគារ និងរីកចម្រើនជាមួយគ្នា។

**អេស៊ីលីដាម៉ូបាល** បានកែលម្អយ៉ាងទូលំទូលាយ និងផ្លាស់ប្តូររូបរាងថ្មី កាន់តែទំនើប ងាយស្រួល និងមានសុវត្ថិភាពខ្ពស់ ជាមួយនឹងមុខងារពិសេសៗជាច្រើន។ ឥឡូវនេះ អតិថិជនទាំងអស់អាចធ្វើប្រតិបត្តិការប្រាក់បញ្ញើ-សន្សំ (សំចៃ ចរន្ត និងមានកាលកំណត់) តាមរយៈ **អេស៊ីលីដាម៉ូបាល** បានភ្លាមៗ ថែមទាំងទទួលបានការប្រាក់ខ្ពស់ទៀតផង។

**ខេអេចឃ្យូអរកូត (KHQR Code)** ផ្តល់នូវភាពងាយស្រួលជាងមុនជូនដល់អ្នកប្រើប្រាស់ក្នុងការធ្វើប្រតិបត្តិការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងទំនុកចិត្តខ្ពស់ រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលជាសមាជិករបស់កម្មវិធីបាគង (**Bakong App**)។

ដើម្បីគាំទ្រដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (ក្នុងអំឡុងពេលនៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩) ឱ្យមានសន្ទនីយភាពបន្ថែមទៀតដើម្បីឆ្លើយតបទៅនឹងតម្រូវការទុនរបស់ខ្លួន ធនាគារជាតិ នៃ កម្ពុជា បានបន្ធូរបន្ថយអនុបាតមួយចំនួនដូចជា៖ សាធនភាព ទ្រនាប់ដើមទុន ប្រាក់បម្រុងកាតព្វកិច្ច។ល។ ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកាត់បន្ថយពន្ធកាត់ទុកលើការប្រាក់កម្ចី ក៏ដូចជាបង្កើតសន្ទនីយភាពបន្ថែមទៀតនៅលើទីផ្សារដែលមានថ្លៃដើមទាប។ កត្តាទាំងនេះបានផ្តល់ឱកាសសម្រាប់ការប្រកួតប្រជែងថ្លៃ ដែលអាចប៉ះពាល់ដល់ចំណូលរបស់ធនាគារក្នុងរយៈពេលខ្លី ប៉ុន្តែវានឹងជួយឱ្យមានភាពរឹងមាំសម្រាប់រយៈពេលវែង។

## ២- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រតិបត្តិការក្នុងវិស័យសេវាកម្ម ដែលការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនអាចអនុវត្តបានចំពោះធនាគារឡើយ។

## ៣- ការវិភាគលើពន្ធ

ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃប្រទេសនីមួយៗ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធមានកាតព្វកិច្ចបង់ពន្ធតាមការកំណត់របស់អាជ្ញាធរពន្ធដារនីមួយៗ។

ការបង់ពន្ធជូនអគ្គនាយកដ្ឋានពន្ធដារមិនត្រឹមតែជាកាតព្វកិច្ច និងការទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ **“មាស”** ពីអគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ២០២២ ដល់២០២៣ ប៉ុណ្ណោះទេ ប៉ុន្តែជាការចូលរួមចំណែកក្នុងសង្គម និងកំណើនសេដ្ឋកិច្ចផងដែរ។

ចំណូលពន្ធគឺជាប្រភពចំណូលដ៏សំខាន់បំផុតសម្រាប់ប្រទេស។ រដ្ឋាភិបាលប្រមូលពន្ធកាន់តែច្រើន ការចូលរួមវិភាគទានកាន់តែច្រើនដល់ការអភិវឌ្ឍប្រទេស។ ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាធនាគារដែលបានបង់ពន្ធដារច្រើនបំផុតលំដាប់ទី៥ ក្នុងចំណោមអ្នកបង់ពន្ធទាំងអស់ក្នុងឆ្នាំ២០២១។ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានមោទកភាពដែលអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើង។

## ៤- ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

ធនាគារមិនមានធាតុ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលខុសពីធម្មតាជាសារវន្តនោះទេ។ ទោះជាយ៉ាងណាក៏ដោយ លក្ខខណ្ឌសេដ្ឋកិច្ចដែលបានរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសវីរុសកូវីដ-១៩ បំប្លែងថ្មី ឆ្លងចូលក្នុងសហគមន៍ក្នុងព្រះរាជាណាចក្រកម្ពុជា អាចជះឥទ្ធិពលដល់សមត្ថភាពសងត្រលប់មកវិញរបស់អតិថិជន ដែលគុណភាពឥណទានរបស់ធនាគារអាចរងផលប៉ះពាល់បន្តិចបន្តួច។

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ដើម្បីចូលរួមគាំទ្រការរីកលូតលាស់អាជីវកម្មរបស់អតិថិជន ធនាគារ អេស៊ីលីដា ភីអិលស៊ី បានផ្តល់អត្រាការប្រាក់មានភាពប្រកួតប្រជែងខ្លាំងចំពោះការស្នើសុំឥណទានថ្មីគ្រប់ប្រភេទ និងដោយកាន់តែមានភាពងាយស្រួល អតិថិជនទាំងអស់អាចដាក់សំណើសុំឥណទានតាមរយៈ **អេស៊ីលីដាម៉ូបាល**។ ជាលទ្ធផល សមតុល្យឥណទានដុលសរុបនៅត្រីមាសទី៤ ឆ្នាំ២០២២ មានការកើនឡើងចំនួន ៤,៣៣២ ទ្រីលានរៀល ឬ ១៩,៥៤% ធៀបនឹងដំណាច់ឆ្នាំ២០២១។

## ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២២ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារមានការប្រែប្រួលក្នុងចន្លោះ ៤.១១០-៤.១៨៦ ក្នុងមួយដុល្លារអាមេរិក ធ្លាក់ចុះបន្តិចបើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន (ចន្លោះពី ៤.០៩៩-៤.១២៤ ក្នុងមួយដុល្លារអាមេរិក) ប៉ុន្តែការប្រែប្រួលនេះស្ថិតនៅក្នុងកម្រិតធម្មតានៃអាជីវកម្ម។ ប៉ាន់ប្រម៉ាណទៅថ្ងៃមុខ តម្លៃប្រាក់រៀលត្រូវបានរំពឹងថានឹងបន្តមានភាពប្រសើរឡើង និងមានស្ថិរភាព នៅពេលដែលសកម្មភាពសេដ្ឋកិច្ចបានស្ទុះងើបឡើងវិញ និងស្ថិតក្រោមការត្រួតពិនិត្យ អន្តរាគមន៍យ៉ាងល្អិតល្អន់ពីធនាគារជាតិ នៃ កម្ពុជា ទោះបីជាអត្រារបស់វាខ្ពស់ជាងបន្តិចបើធៀបទៅនឹងមុនកូវីដ-១៩។

ចំពោះធនាគារ អេស៊ីលីដា ភីអិលស៊ី ធនាគារបានធ្វើការវាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងជាប្រចាំថ្ងៃ ដោយរក្សាស្ថានភាពរូបិយប័ណ្ណចំហតូចល្មម អនុវត្តតាមតម្រូវការនៃបទប្បញ្ញត្តិរបស់ធនាគារជាតិ នៃ កម្ពុជា និងគោលនយោបាយហានិភ័យផ្ទៃក្នុងរបស់ខ្លួន។ ដូច្នេះ មិនមានផលប៉ះពាល់ជាសារវន្តដល់ធនាគារឡើយ។

អត្រាការប្រាក់នៃទីផ្សារក្នុងស្រុក និងអន្តរជាតិ បានបន្តកើនឡើងបន្តិច បន្ទាប់ពីការកើនឡើងនៃអត្រាមូលនិធិសហព័ន្ធនៃសហរដ្ឋអាមេរិក ដោយសារតែអត្រាអតិផរណារបស់សហរដ្ឋអាមេរិកនៅតែខ្ពស់ ដែលរងផលប៉ះពាល់ពីការប្រែប្រួលនៃការផ្គត់ផ្គង់ជាសកល បង្កឡើងពីបញ្ហាសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែន។

ធនាគារ អេស៊ីលីដា បាននិងកំពុងដំណើរការអាជីវកម្មរបស់ខ្លួនស្ទើរតែទាំងស្រុង ដោយធ្វើការផ្គូផ្គងរវាងទ្រព្យសកម្ម និងបំណុលលើអត្រាការប្រាក់ថេរ។ ដូច្នេះ ផលប៉ះពាល់នៃការប្រែប្រួលអត្រាការប្រាក់លើអាជីវកម្មរបស់ធនាគារមានតិចតួចបំផុត ហើយការប្រែប្រួលនេះ ត្រូវបានត្រួតពិនិត្យជាប្រចាំ ដើម្បីចាត់វិធានការសមស្រប និងទាន់ពេលវេលា ដើម្បីចៀសវាងផលប៉ះពាល់ដល់អាជីវកម្មរបស់ធនាគារ។

ដោយឡែកចំពោះប្រតិបត្តិការជួញដូរនានា ដែលមានទម្រង់ជាទំនិញ (Commodities) ធនាគារមិនមានផ្តល់សេវាបែបនោះទេ។ ដូច្នេះ មិនមានផលប៉ះពាល់ដល់ធនាគារឡើយ។

## ង- ផលប៉ះពាល់នៃអតិផរណា

សម្រាប់ឆ្នាំ២០២២ អត្រាអតិផរណាជាមធ្យម ត្រូវបានព្យាករប្រហែល ៥,៣% ដោយសារតែការកើនឡើងនៃតម្លៃប្រេងឥន្ធនៈ និងអាហារ ដែលរងផលប៉ះពាល់ពីសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែន។ ជាទូទៅ វានឹងមានផលប៉ះពាល់ខ្លះដល់ការចំណាយរបស់អ្នកប្រើប្រាស់ ប៉ុន្តែផលប៉ះពាល់នឹងត្រូវបានទូទាត់ដោយការរំពឹងទុកពីការប្រសើរឡើងវិញនៃសេដ្ឋកិច្ច។ អតិផរណាត្រូវបានព្យាករថានឹងថយចុះមកត្រឹម ២,៥% នៅឆ្នាំ២០២៣។ ទោះជាយ៉ាងណាក៏ដោយ ប្រតិបត្តិការរបស់ធនាគារមិនពាក់ព័ន្ធដោយផ្ទាល់ទៅនឹងកម្រិតអតិផរណានោះទេ។ ដូច្នេះ ផលប៉ះពាល់គឺតិចតួចបំផុត និងក្នុងកម្រិតអាចគ្រប់គ្រងបាន។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល

- **គោលនយោបាយសេដ្ឋកិច្ច៖**

ធនាគារជាតិ នៃ កម្ពុជា បានផ្តល់ជារបាយការណ៍ថា កំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២២ បានបន្តងើបឡើងក្នុងអត្រា ៥,១% ដែលគាំទ្រជាចម្បងដោយការបើកទូលាយសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកឡើងវិញ និងកំណើនតម្រូវការខាងក្រៅ ដែលរួមមាន៖

១. វិស័យកម្មន្តសាលសម្រេចបានកំណើនរឹងមាំ ដែលក្នុងនោះផលិតផលកាត់ដេរសម្រាប់នាំចេញកើន ៦៤,៣% ផលិតផលមិនមែនកាត់ដេរសម្រាប់នាំចេញកើន ១,១ ដង និងផលិតផលកម្មន្តសាលសម្រាប់បម្រើទីផ្សារក្នុងស្រុក កើន ៨៨,៥%។
២. វិស័យទេសចរណ៍មានកំណើនល្អ ដោយភ្ញៀវអន្តរជាតិបានកើនឡើងខ្ពស់ជាងការរំពឹងទុកដល់ ២,២ លាននាក់ ថ្វីបើនៅមានកម្រិតត្រឹម ១/៣ នៃគ្រាមុនវិបត្តិក៏ដោយ ខណៈដែលទេសចរក្នុងស្រុកបានវិលមកប្រក្រតីភាពទាំងស្រុង។
៣. វិស័យសំណង់ និងអចលនទ្រព្យមានកំណើនទាបត្រឹម ០,៨% និង ០,៥% រៀងគ្នា ដែលគាំទ្រដោយកំណើនតម្រូវការក្នុងស្រុក។
៤. វិស័យកសិកម្មបន្តកើនឡើងក្នុងល្បឿនយឺតត្រឹម ០,៧% ដែលបណ្តាលមកពីទឹកភ្លៀងធ្លាក់លឿននិងមានបរិមាណច្រើន និងការកើនឡើងថ្លៃដើមផលិត ដោយសារការឡើងថ្លៃប្រេងឥន្ធនៈ និងជីកសិកម្ម។
៥. ជញ្ជីងទូទាត់ត្រូវបានប៉ាន់ស្មានថាមានភាពប្រសើរឡើងដោយមានអតិរេក ២៩៨,៨ លានដុល្លារអាមេរិក ដោយសារលំហូរចូលនៃគណនីហិរញ្ញវត្ថុ និងការថយចុះឱនភាពគណនីចរន្ត និងដើមទុន។ ទុនបម្រុងអន្តរជាតិមានកម្រិតខ្ពស់គ្រប់គ្រាន់ ទោះបីជាបានថយចុះបន្តិចក្តី ដោយមានចំនួនប្រមាណ ១៧,៨ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ៧ខែ នៃការនាំចូលទំនិញ និងសេវាសម្រាប់គ្រាបន្ទាប់ ខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍ។

ស្របគ្នានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានព្យាករផងដែរថា សេដ្ឋកិច្ចកម្ពុជាត្រូវរំពឹងថានឹងកើនឡើងចំនួន ៥,៤% សម្រាប់ឆ្នាំ២០២២ (ថយចុះពី ៥,៦% កាលពីដើមឆ្នាំ) ដែលរួមចំណែកដោយ៖

១. តម្រូវការទីផ្សារធំៗរបស់កម្ពុជា នៅតែមានតម្រូវការ ព្រមទាំងសកម្មភាពធុរកិច្ច និងខ្សែច្រវាក់ផ្គត់ផ្គង់ផលិតកម្មក្នុងស្រុកមានភាពល្អប្រសើរ។
២. រាជរដ្ឋាភិបាលបានបន្តអនុវត្តវិធានការអន្តរាគមន៍ ដូចជាការឧបត្ថម្ភសាច់ប្រាក់ដល់ប្រជាជនងាយរងគ្រោះ និងការផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករ-និយោជិតក្នុងអំឡុងពេលព្យួរការងារជាដើម។
៣. ស្ថានភាពសេដ្ឋកិច្ចបាននឹងកំពុងងើបឡើង តាមរយៈការកើនឡើងនៃភ្ញៀវទេសចរអន្តរជាតិ គម្រោងវិនិយោគលើវិស័យឧស្សាហកម្ម និងការបន្តកើនឡើងនូវផលិតកម្មក្នុងស្រុក ស្របពេលដែលការនាំចេញបន្តមានកំណើនល្អ លើផលិតផលកាត់ដេរ និងផលិតផលមិនមែនកាត់ដេរ។ [(១), (២)]

យោងតាមព័ត៌មានដែលបានចុះផ្សាយនៅក្នុងអំឡុងខែធ្នូ ស្ថាប័នល្បីល្បាញមួយចំនួននៅបន្តព្យាករ GDP ឆ្នាំ២០២២ របស់កម្ពុជាផងដែរ។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានរក្សាការព្យាករសេដ្ឋកិច្ចរបស់កម្ពុជាចំនួន ៥,៣% នៅឆ្នាំ២០២២ និងបានទម្លាក់ការព្យាករកាលពីដើមឆ្នាំពី ៦,៥% មក ៦,២% សម្រាប់ឆ្នាំ២០២៣ ដោយសារកំណើនខ្សោយរបស់សេដ្ឋកិច្ចសកល។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ទោះបីជាមានសម្ពាធថ្មីក៏ដោយ ការស្ទុះងើបឡើងវិញត្រូវបានព្យាករថានឹងបន្តទៅមុខ កំណើន GDP ពិត ត្រូវបានព្យាករថានឹងមានចំនួន ៥% នៅឆ្នាំ២០២២ បន្ទាប់ពីដំណើរការនាំចេញដ៏រឹងមាំកាលពីដើមឆ្នាំ និងជិត ៥,៥០% ក្នុងឆ្នាំ២០២៣ ដែលត្រូវបានគាំទ្រដោយការបន្តការងើបឡើងវិញនៃវិស័យទេសចរណ៍ និងការគាំទ្រគោលនយោបាយដែលកំពុងបន្ត បើទោះបីជាត្រូវបានបង្អាក់ដោយសម្ពាធខាងក្រៅ និងផលប៉ះពាល់នៃការកើនឡើងថ្លៃទៅលើចំណូលពិតប្រាកដក្រោយដកពន្ធ។ អតិផរណាត្រូវបានរំពឹងថាឡើងដល់កំពូលនៅឆ្នាំនេះ ទាបជាងនេះនៅឆ្នាំ២០២៣ ហើយនឹងធ្លាក់ចុះបន្ថែមទៀតបន្ទាប់ពីនោះ ដោយសន្មតថាវានៅតែត្រូវបានបង្ខាំងភាគច្រើនចំពោះទំនិញនាំចូល។ ធនាគារពិភពលោកព្យាករកំណើនសេដ្ឋកិច្ច ៤,៨% ក្នុងឆ្នាំ២០២២ ខណៈដែលការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចក្រោយការរាតត្បាតរីករាលដាល ដោយសារការស្ទុះងើបឡើងវិញនៃវិស័យទេសចរណ៍ នេះបើតាមរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជារបស់ធនាគារពិភពលោកសម្រាប់ខែធ្នូ ឆ្នាំ២០២២ ដែលបានសរសេរថា ឧស្សាហកម្មកាត់ដេរ ទំនិញធ្វើដំណើរ និងការនាំចេញស្បែកជើងរបស់កម្ពុជាមានភាពធន់។ វិស័យសេវាកម្ម ជាពិសេសការធ្វើដំណើរ និងទេសចរណ៍ ធ្វើបានយ៉ាងល្អ ចាប់តាំងពីការដាក់ចេញនូវយុទ្ធសាស្ត្រ "រស់នៅជាមួយកូវីដ-១៩" នៅចុងឆ្នាំ២០២១ ហើយការមកដល់របស់ភ្ញៀវអន្តរជាតិសរុបបានកើនឡើងជាលំដាប់ ដោយឈានដល់ ១,២លាននាក់ ក្នុងរយៈពេល៩ខែដំបូងនៃឆ្នាំ២០២២។ ទំនុកចិត្តលើអាជីវកម្ម និងអ្នកប្រើប្រាស់បានកើនឡើង ហើយការវិនិយោគទាំងក្នុង និងក្រៅប្រទេសបានកើនឡើង។ កំណើនសេដ្ឋកិច្ចត្រូវ

បានព្យាករថានឹងកើនដល់ ៥,២% នៅឆ្នាំ២០២៣ ដោយសារការកើនឡើងនៃការជួលគាំទ្រដល់ការកើនឡើងនៃការប្រើប្រាស់ក្នុងស្រុក និងនៅពេលដែលអតិផរណាធ្លាក់ចុះ។ [(៣), (៤), (៥)]

- **គោលនយោបាយសារពើពន្ធ៖**

សម្រាប់ឆ្នាំ២០២២ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវវិធានការសំខាន់ៗ និងជាយុទ្ធសាស្ត្រសំខាន់ៗដូចតទៅ៖

១. បន្តពង្រឹងការអនុវត្តវិធានការចាំបាច់នានាដូចមានកំណត់ក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣។

២. បន្តការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសារពើពន្ធថ្មី ដោយចាប់ផ្តើមបើកការពិភាក្សាកម្រិតក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីឱ្យការរៀបចំមានភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡា ព្រមទាំងឆ្លើយតបនឹងការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ធានាភាពច្បាស់លាស់ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព នីត្យានុកូលភាព និងសង្គតិភាពនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ។

៣. រៀបចំយន្តការដើម្បីគ្រប់គ្រងចំណូលក្នុងវិស័យធំៗដែលជាសក្តានុពលសម្រាប់ចំណូលពន្ធ រួមមាន៖

(ក) បន្តពង្រឹងការអនុវត្តកាតព្វកិច្ចដំឡើងឧបករណ៍វាស់ចំណុះស្រាបៀរ និងភេសជ្ជៈគ្មានជាតិអាល់កុលរបស់សហគ្រាសផលិតក្នុងស្រុក (Flowmeter)

(ខ) ពង្រឹងកិច្ចសហការជាមួយមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC)

(គ) រៀបចំយន្តការកំណត់អត្តសញ្ញាណអចលនទ្រព្យ (Property ID) ដើម្បីបញ្ជាក់ថាអចលនទ្រព្យនីមួយៗបានបង់ពន្ធរួចរាល់ ចៀសវាងការលក់ដូរអចលនទ្រព្យដោយមិនបានបង់ពន្ធ

(ឃ) រៀបចំធ្វើទំនើបកម្មយន្តការត្រួតពិនិត្យតាមដានការដឹកជញ្ជូនផលិតផលតេលសិលា និងគ្រឿងសំណង់ តាមរយៈការដំឡើងឧបករណ៍តាមដាន (GPS និង RFID) តាមរថយន្តដឹកជញ្ជូន និងស្ថានីយ ដើម្បីពង្រឹងការអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលដែលមានអភិបាលកិច្ចល្អជាស្នូល ការលើកកម្ពស់អនុលោមភាព និងធានាបាននូវការប្រកួតប្រជែងដោយស្មើភាព

(ង) រៀបចំយន្តការសហការជាមួយក្រុមហ៊ុនផ្តត់ផ្គង់សេវាអ៊ីនធើណែត (ISPs) ដែលកំពុងប្រតិបត្តិការក្នុងស្រុក ដើម្បីចាត់វិធានការគ្រប់គ្រងលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-commerce)។

៤. បន្តពង្រឹងការអនុវត្តវិធានការទារបំណុលពន្ធរ៉ាំរ៉ៃ និងគោរពស្នើសុំគោលការណ៍សម្រេចទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះករណីសហគ្រាសរឹងរូសពុំព្រមចូលខ្លួនមកទូទាត់បំណុលពន្ធ។

៥. បន្តពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធលើវិស័យដែលនៅមានសក្តានុពល ដើម្បីធានាបាននូវប្រសិទ្ធភាព តម្លាភាព និងការប្រកួតប្រជែងដោយស្មើភាព។

៦. ជំរុញសហគ្រាសក្នុងវិស័យល្បែងពាណិជ្ជកម្ម (កាស៊ីណូ) ឱ្យចូលខ្លួនមកចុះបញ្ជីពន្ធដារ និងអនុវត្តកាតព្វកិច្ចសារពើពន្ធឱ្យបានត្រឹមត្រូវ ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។

៧. បន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងកម្មវិធី តាមរយៈការអភិវឌ្ឍ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធ និងកម្មវិធីថ្មីៗ។

៨. បន្តពង្រឹងការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ កំណែទម្រង់ និងទំនើបកម្មរដ្ឋបាលសារពើពន្ធ និងបន្តពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធ តាមរយៈការរៀបចំកម្មវិធីរៀនអំពីពន្ធដារតាមអនឡាញ (Tax Education) កិច្ចប្រជុំ សិក្ខាសាលាវិបស្សនាគេហទំព័រ ទំព័រទំនាក់ទំនងសង្គម និងការផ្សាយផ្ទាល់តាមអនឡាញ ជាពិសេសការរៀបចំកម្មវិធី “ពន្ធដារកម្ពុជា” ដោយមានការជួបជជែកជាមួយអ្នកជាប់ពន្ធផ្ទាល់តាមប្រព័ន្ធបណ្តាញសង្គម GDT Facebook Live, សេវាឆ្លើយតបតាមប្រព័ន្ធទូរស័ព្ទ Call Center ១២៧៧, កម្មវិធី GDT Live Chat ជាដើម។

៩. បន្តការងារកែទម្រង់ធនធានមនុស្ស និងបន្តពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងត្រូវមានភាពទន់ភ្លន់តែម៉ឺងម៉ាត់ ដោយផ្អែកលើទិដ្ឋភាពច្បាប់ក្នុងការផ្តល់សេវាជូនអ្នកជាប់ពន្ធ និងការគ្រប់គ្រងប្រមូលចំណូលពន្ធ។ [(៦)]

សម្រាប់រយៈពេល១២ខែ ឆ្នាំ២០២២ ទទួលបានលើសផែនការ ដែលចំណូលពន្ធ-អាករប្រមូលបានមានចំនួន ១៣.៩៩៣,២០ ប៊ីលានរៀល (ប្រមាណជា ៣.៤៥៥,១១ លានដុល្លារអាមេរិក) ស្មើនឹង ១២២,៥៤% នៃផែនការប្រចាំឆ្នាំ ក្នុងនោះ ចំណូលពន្ធ-អាករប្រមូលបានដោយនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ មានចំនួន ១០.៤១១,៩៦ ប៊ីលានរៀល (ប្រមាណជា ២.៥៧០ លានដុល្លារអាមេរិក) ស្មើនឹង ១២០,៦១% នៃផែនការប្រចាំឆ្នាំ ប្រមាណជា ៧៥% នៃចំណូលពន្ធដារសរុប របស់អគ្គនាយកដ្ឋានពន្ធដារ។ [(៧)]

- **គោលនយោបាយរូបិយវត្ថុ៖**

សម្រាប់ឆ្នាំ២០២២ ធនាគារជាតិ នៃ កម្ពុជា បានកំណត់អនុវត្តន៍គោលនយោបាយរូបិយវត្ថុចំនួន៥ ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តាកំណើនសេដ្ឋកិច្ចជាតិ រួមមាន៖

(១) គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឱ្យស្ថិតក្នុងកម្រិតសមស្រប

(២) រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដើម្បីរួមចំណែកស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជន

(៣) លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលតាមយន្តការទីផ្សារ

(៤) អភិវឌ្ឍឧបករណ៍គោលនយោបាយរូបិយវត្ថុថ្មីៗ និង

(៥) ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ។ [៨]


ឯកសារយោង:

(១) https://www.nbc.org.kh/download_files/publication/annual_rep_kh/Annual%20Report%202022%20Publish_KHM.pdf

(២) https://mef.gov.kh/documents-category/publication/economic-finance-statistic-bulletin/ Release on 22-Nov-2022

(៣) https://www.khmertimeskh.com/501155788/adb-retains-cambodias-growth-forecast-at-5-3-percent-in-2022-and-6-2-percent-in-2023-down-by-0-3-percent/

(៤) https://www.imf.org/en/News/Articles/2022/12/16/pr22439-imf-executive-board-concludes-2022-article-iv-consultation-with-cambodia

(៥) https://www.worldbank.org/en/news/press-release/2022/12/07/cambodia-s-economy-is-recovering-but-could-face-headwinds-world-bank-report-says

(៦) https://www.tax.gov.kh/u6rhf7ogbi6/gdtstream/c8e3215e-98ef-4dc0-9b95-5b1bf767741e

(៧) https://www.tax.gov.kh/u6rhf7ogbi6/gdtstream/a5b57ae4-c5e7-469a-989c-dee6d907d52f

(៨) https://www.nbc.org.kh/download_files/publication/annual_rep_kh/Annual%20Report%202021%20Publish.pdf


**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

ថ្ងៃសុក្រ ៥រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣

បានអាន និងឯកភាព

ហត្ថលេខា

**ឆាយ សឿន**

**ប្រធានក្រុមប្រឹក្សាភិបាល**

អេស៊ីលីដា
ACLEDA BANK